# ជំពូក ១០

## សន្និដ្ឋាន និង អនុសាសន៍

## CONCLUSIONS AND RECOMMENDATIONS

Draft

Draft

# ជំពូកទី ១០

# សន្និដ្ឋាន និង អនុសាសន៍

## ១០.១ សន្និដ្ឋាន លើគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១

ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមលើគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន KTC ប្រទេសកូរ៉េ និង SINOHYDRO ប្រទេសចិន ដែលមានក្រុមហ៊ុន HEC ជាទីប្រឹក្សាបច្ចេកទេស សិក្សាសមិទ្ធិលទ្ធភាព ហើយបានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ អាចធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

- ការវិនិយោគលើគម្រោងនេះមានចំនួន ២៣២,២១ លានដុល្លារអាមេរិក។ ក្នុងទុនវិនិយោគនេះ ក្រុមហ៊ុនបានគិតគូរអំពី ថវិកាសម្រាប់ការអនុវត្តវិធានការការពារបរិស្ថានចំនួន ៨,៦៨៩ លានដុល្លារអាមេរិកផងដែរ ក្នុងនោះមានមូនិធិបរិស្ថាន និងសង្គម ៨២៦.៤៨០ដុល្លារអាមេរិកផងដែរ (សម្រាប់រយៈពេល៣៥ឆ្នាំ)។
- វារីអគ្គិសនីនេះមានកម្លាំងសរុប ៨០ MW ។
- តម្លៃលក់អគ្គិសនីក្នុង ១KWh គឺ ៧,៨៧ សេន(ដុល្លារ)អាមេរិក។
- គម្រោងនេះមានផែនការសាងសង់រយៈ៤ឆ្នាំ។ យោងតាម ការគណនាចំណូលចំណាយ របស់ក្រុមហ៊ុន SINOHYDRO រយៈពេលប្រតិបត្តិគម្រោងគឺ ៣៥ឆ្នាំ។
- គម្រោងនេះត្រូវការផ្ទៃដីចំនួនសរុប ៩.៣៥៥ហ.ត សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីទំនប់អាគារថាមពល ផ្លូវថ្នល់ ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ២៣០គ.វ៉ ភ្ជាប់ទៅបណ្តាញខ្សែ ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់។
- ក្រុមការងារ SAWAC បានចែកតំបន់គម្រោងជា ៤តំបន់ គឺតំបន់១ជាតំបន់អាង៨.៥៩១ហ.ត, តំបន់២ជាតំបន់ហេដ្ឋារចនា សម្ព័ន្ធគម្រោង៥៥៩,៩១ហ.ត, តំបន់៣ជាតំបន់ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉មាន១៣,៦៤ហ.ត និងតំបន់៤ជាតំបន់សម្រាប់តាំងលំនៅឋានថ្មី របស់ប្រជាពលរដ្ឋប៉ះពាល់ដោយសារអាង មាន ១៩០,៤៥ហ.ត (ដោយមិនគិតតំបន់បំរុងទុក ៥០ ហ.ត ទៀតទេ)។
- ការសាងសង់របស់គម្រោងនេះនឹងធ្វើឱ្យប៉ះពាល់ផ្ទៃដីព្រៃឈើសរុប៦,០០៧,២៤ហ.ត ក្នុងនោះការប៉ះពាល់ដោយសារអាងស្តុកទឹក (តំបន់១) ៥.៨៣៥,៦ហ.ត (ព្រៃសោង៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង ៨៥០,២៥ហ.ត និងព្រៃល្បោះ ៤.២៥៣ហ.ត), តំបន់២ប៉ះពាល់ព្រៃឈើ១២០.២៥ហ.ត (ព្រៃសោង ១១៩,១៨ហ.ត ព្រៃពាក់ កណ្តាលស្រោង១,០៧ ហ.ត និងព្រៃល្បោះ ០ ហ.ត), តំបន់៣ជាតំបន់ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉ ប៉ះពាល់ព្រៃឈើ ១២,៨៩ ហ.ត(ព្រៃសោង ១១,៣១ ហ.ត ព្រៃពាក់កណ្តាលស្រោង ១,៥៨ ហ.ត និងព្រៃល្បោះ០ ហ.ត) និងតំបន់៤គឺតំបន់សម្រាប់តាំងលំនៅឋានថ្មីប៉ះពាល់ព្រៃឈើ៣៨,៥ហ.ត (ព្រៃសោង ០ ហ.ត ព្រៃពាក់កណ្តាលស្រោង ០ ហ.ត និងព្រៃល្បោះ ៣៨,៥ ហ.ត)។
- គម្រោងនេះនឹងអាចធ្វើឱ្យបាត់បង់ទាំងស្រុងនូវព្រៃស្រោង ដែលមានផ្ទៃដីសរុប ៨៦៥,៤៦ ហ.ត ព្រៃពាក់កណ្តាលស្រោង សរុប៨៥០,២៥ ហ.ត ព្រៃល្បោះសរុប ៤.២៩១,៥ហ.ត មានដង់ស៊ីតេមាឌជាមធ្យម ៥១,៥៦ ម$^3$/ហ.ត (គិតអង្កត់ផ្ចិត ឈើពី១០ស.មឡើងទៅ) និងឈើដែលមានអង្កត់ ផ្ចិត៣០ស.ម គឺ៣៤,៦០ ម$^3$/ហ.ត។ ការបាត់បង់ ព្រៃឈើទាំងស្រុង ក្នុងតំបន់អាង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី នឹងធ្វើការដេញថ្លៃបង់ចូលជា ថវិកាជាតិដោយតម្លាភាព។ ***សម្គាល់:*** *តម្លៃនៃការបាត់ព្រៃឈើនេះ មាន ១.០៤៩.៥៥១ ដុល្លារ /ឆ្នាំ* (លម្អិតមើលតារាង ៩-១ ខាងលើ)

Draft

- យោងតាមការសិក្សាព្រៃឈើនៅក្នុងតំបន់គម្រោង មានព្រៃឈើ៣ប្រភេទគឺៈ ព្រៃស្រោងមានពូជឈើ៩៦ប្រភេទ ដែលក្នុងនោះមានឈើ ៧ប្រភេទ ដូចជា អង្កត់ខ្មៅ, ត្រយឹង, ធ្នង់, តាត្រាវ, បេង, នាងនួន, និងគ្រើល (មើលតារាង ៥-២៧)។ ព្រៃពាក់កណ្តាលស្រោងមាន៧៦ប្រភេទ ដែលក្នុងនោះមានឈើ ៣ប្រភេទ ដូចជា ត្រយឹង, អង្កត់ខ្មៅ, និងធ្នង់ (មើលតារាង ៥-២៨) និងព្រៃល្បោះ មានពូជឈើ ៨៨ប្រភេទ ដែលក្នុងនោះ មានឈើ ៥ប្រភេទ ដូចជា ត្រយឹង, អង្កត់ខ្មៅ, ហៃសាន, តាត្រាវ, និងគ្រើល (មើលតារាង ៥-២៩)។
- នៅក្នុងតំបន់គម្រោងក្រុមការងារបានរកឃើញពពួកសត្វព្រៃ រួមមានៈ ថនិកសត្វចំនួន ៤៤ប្រភេទ បក្សី១២០ប្រភេទ ឧរុង្គសត្វនិង ថលជលិកសត្វ៦៣ប្រភេទ និងត្រីទឹកសាប ៨៣ប្រភេទ ។ ដូចនេះអាចមានការប៉ះពាល់ដល់សត្វព្រៃ និងជម្រករបស់វា (លម្អិតមានចែងក្នុងជំពូក៥កថាខ័ណ្ឌ៥.១.២.២) ក៏ប៉ុន្តែក្រុមហ៊ុននឹងបង្កលក្ខណៈងាយស្រួលសម្រាប់ ការបំលាស់ទីរបស់ជីវៈចំរុះទាំងនោះ ទៅកន្លែងព្រៃនៃតំបន់អភិរក្សក្បែរនោះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការនានាក្នុងតំបន់គម្រោង។ **បញ្ជាក់ៈ** ក្រុមហ៊ុនគ្រោងព្រលែងកូនត្រីប្រភេទងាយរងគ្រោះថ្នាក់ប្រភេទ ជិតផុតពូជដោយព្រលែងវាទៅក្នុងតំបន់អាង អូរ ស្ទឹង ក្នុង និងក្បែរតំបន់គម្រោង។
- ក្នុងតំបន់អាង (តំបន់១) មានការប៉ះពាល់ដល់ដីកសិកម្ម (ដីផលិតកម្ម) ចំនួន ៩៣២,១២ហ.ត ដីបុស្ស ១.០៦៨,៣៩ ហ.ត និងដីលំនៅដ្ឋាន ៣៨,៤៤ហ.ត ដែលជារបស់ប្រជាពលរដ្ឋ ៣៤៧គ្រួសារ។ ក្នុងតំបន់នេះមានផ្ទះប្រជាជន ៩២ ខ្នង ចែកជា ៩ប្រភេទផ្ទះ ជារបស់៧៨គ្រួសារ(គ្រួសារខ្លះមានផ្ទះលើសពី១ខ្នង)។
- ក្នុងតំបន់អាង (កំរឹតកម្ពស់ EL:180m)នេះដែរមានការប៉ះពាល់ដល់ដំណាំឈើសេដ្ឋកិច្ច ដូចជាដំណាំឈើមិនទាន់ឱ្យផល (ប្រភេទ១+ប្រភេទ២) សរុបចំនួន ៥៤.៥៦១ដើម/គុម្ព ដំណាំឈើឱ្យផល(ប្រភេទ៣)២៤.០៥៧ ដើម/គុម្ព ដែលជារបស់ ១២៨ គ្រួសារ។
- ការប៉ាន់ប្រមានតម្លៃនៃសំណង និងការទូទាត់ផ្សេងៗដល់អ្នកប៉ះពាល់ដោយសារគម្រោងទាំង៣៤៧គ្រួសារ រួមទាំងការបង្កើតកន្លែងតាំងលំនៅឋានថ្មីផង មានសរុបចំនួន ៦.៨៣៣.០១៦ ដុល្លារអាមេរិក។
- តំបន់អាងនេះក៏នឹងត្រូវប៉ះពាល់ផងដែរដល់សម្បត្តិសាធារណៈដូចជា, ប៉ះពាល់ផ្លូវរទេះ (ផ្លូវលំចាស់) ចូលទៅអន្លង់ក្រូច និង អន្លង់យួត ចំនួន ១៦.៧គ.ម ទៀតផង។
- ការសាងសង់ផ្លូវចូលទៅតំបន់គម្រោងដល់ទីតាំងទំនប់មេ មិនមានការប៉ះពាល់ដល់ប្រជាពលរដ្ឋទេ។
- ចំពោះការសាងសង់ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉ពីអាគារថាមពលទៅភ្ជាប់ជាមួយបណ្តាញខ្សែ២៣០គ.វ៉ របស់ក្រុមហ៊ុនចិន អូរសោម-ពោធិ៍សាត់ប្រវែង៥គ.មនោះ នៅតំបន់តាមគន្លងខ្សែបញ្ជូនចរន្ត២៣០គ.វ៉ ក៏មិនប៉ះពាល់ដល់ប្រជាពលរដ្ឋទេ។
- គម្រោងនេះ នឹងមានការខ្វះខាតទឹករក្សាជីវៈចំរុះរបស់កំណាត់ស្ទឹងពោធិ៍សាត់នៅចន្លោះទំនប់ និងអគារថាមពល ចម្ងាយប្រមាណ៩,២គ.ម ក្នុងពេលប្រតិបត្តិ និងថែទាំគម្រោង។
- យោងតាមការវិភាគគុណភាពទឹកស្ទឹងពោធិ៍សាត់ ២កន្លែងក្នុងតំបន់គម្រោង ទាំងរដូវប្រាំង និងវស្សាមុនពេលសាងសង់ គម្រោងនេះបង្ហាញថា ប្រភពទឹកស្ទឹងនេះមានការបំពុលមិនធ្ងន់ធ្ងរទេពីមនុស្ស ដែលរស់នៅតំបន់ខាងលើខ្សែទឹកដូចជា ប្រមោយទីរួមស្រុកវាលវែង ជាដើម ។ ការបំពុលទឹកនេះ មានប៉ារ៉ាម៉ែត្រមួយចំនួន ដូចជា Fe, Mn, ភាពល្អក់ និង Total Coliform ដែលលើសស្តង់ដាររបស់ ក្រសួងរ៉ែ និងថាមពល និងក្រសួងបរិស្ថាននេះដោយសារធម្មជាតិក្នុងតំបន់គម្រោង និងដោយសារការរស់នៅ និងការធ្វើកសិកម្មរបស់មនុស្សនៃតំបន់ខាងលើខ្សែទឹក។
- តំបន់ផ្ទៃរងទឹកភ្លៀងនៃស្ទឹងពោធិ៍សាត់គឺតត្រឹមទំនប់មេ មានក្រឡាផ្ទៃ ១.២៦៣ គ.ម$^2$ ។ ដែលមានលំហូរគិតតាមប្រូបាបីលើគេ ១០.០០០ ឆ្នាំ គឺ ២.៦៦០ ម$^3$/វិន. និង៥០០ ឆ្នាំ គឺ ២.០២៤ ម$^3$/វិន. ។

- តាមការសិក្សាកម្រិតធារទឹកនៅទីតាំងទំនប់មេរបស់ក្រុមហ៊ុន HEC បានឱ្យដឹងថាកម្រិតធារទឹកមធ្យមក្នុង១ឆ្នាំ សម្រាប់ខួប៣០ឆ្នាំ នៅទំនប់មេ នារដូវវស្សាចន្លោះពីខែឧសភា-តុលា (រដូវវស្សា) មាន២១,៥ម$^{៣}$/វិន.។ កម្រិតធារទឹកធំជាងគេជា មធ្យមប្រចាំខែ គឺនៅខែតុលា ឆ្នាំ២១០ គឺ៣៨៩,២ $m^3/s$។ កម្រិតធារទឹកអប្បបរមាជាមធ្យមប្រចាំខែ នៅខែកុម្ភៈ ឆ្នាំ២០០៦ និងមិនា ឆ្នាំ១៩៨១ គឺ០,៦ $m^3/s$។ ចំពោះកម្រិតធារទឹកមធ្យមសម្រាប់ខួប៣០ឆ្នាំ នៅរដូវប្រាំង ពីខែវិច្ឆិកា ដល់ខែមេសា វិញមាន ៦២,៨ $m^3/s$។
- ចំពោះស្ទឹងពោធិ៍សាត់ចាប់ពីទីតាំងទំនប់មេដល់អាគារថាមពល ប្រវែងប្រមាណ៩,២គ.ម និងមានការខ្វះខាត់ទឹកសម្រាប់រក្សា ជីវចំរុះរបស់ស្ទឹងនេះ ហើយត្រូវក្រុមហ៊ុនមានគម្រោងធ្វើកន្លែងបង្ហូរទឹកមកខាងក្រោមតំបន់នេះចំនួន១,៣ម$^{៣}$/វិន. ទាំង ប្រាំង និងវស្សា (មានសំណង់បង្ហូរទឹកសម្រាប់បរិស្ថាន ដែលខាងក្រោមវាមានបំពាក់ ទួរប៊ីនផលិតអគ្គិសនីកំលាំង ៨០០kW, ធារទឹក១,៣ ម$^{៣}$/វិនាទី ដែលមានចំងាយ ប្រមាណ៣គ.ម ពីទីតាំងទំនប់មេ)។
- នៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងនៃស្ទឹងពោធិ៍សាត់ ការសាងសង់គម្រោងវារីអគ្គិសនីនេះ នៅស្ទឹងពោធិ៍សាត់ខាងលើខ្សែទឹក និងគម្រោងធារាសាស្រ្ត៣ កន្លែងទៀតកាត់ស្ទឹងនេះដែរគឺ ដំណាក់ឈើក្រំ (នឹងសាងសង់ឆ្នាំ២០១៧) ដំណាក់អំពិល និងចារឹកនៅខ្សែទឹកខាងក្រោម។ ជាងនេះ ទៅទៀត នៅតាមដៃស្ទឹងពោធិ៍សាត់នេះមានគម្រោងធារាសាស្រ្ត ២ កន្លែងទៀតគឺ ទំនប់៣ និងទំនប់៥ នៅស្រុកក្រវ៉ាញ សកម្មភាព ទាំងនេះអាចធ្វើឱ្យមានបន្ទុំផលប៉ះពាល់បរិស្ថានសំខាន់មួយចំនួនផងដែរ ដូចជាការប៉ះពាល់ ដល់របបទឹកស្ទឹងពោធិ៍សាត់ ប៉ះពាល់ដល់ការបំលាស់ទីរបស់ជីវសាស្រ្តរស់នៅក្នុងទឹក ជាពិសេសពពួកត្រីទឹកសាប កន្ធាយ ក្រពើ ភ្នំជាដើម។ ក៏ប៉ុន្តែគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានផលប៉ះពាល់វិជ្ជមានទៅវិញ ក្នុងដំណាក់កាលប្រតិបត្តិគម្រោង ដោយសារគម្រោងធ្វើការព្រលែងទឹកយ៉ាង ហោចណាស់ ៤០ ម$^{៣}$/វិន. ក្នុងការផលិតអគ្គិសនី ដោយមួយទួរប៊ីនដែលនៅរដូវប្រាំង ដែលស្ទឹងនេះមានតែ ០.៦ម$^{៣}$/វិន. ត្រង់ទីតាំងទំនប់ (បើការផលិតអគ្គិសនីតាំង ២ ទួរប៊ីន នោះបរិមាណទឹកឡើងដល់ ៨០ម$^{៣}$/វិន) ដែលធ្វើឱ្យប្រសើរឡើងនៃការផ្គត់ផ្គង់ទឹក កសិកម្ម ដល់ប្រពន្ធ័ ធារាសាស្រ្តដំណាក់ឈើក្រំ ដំណាក់អំពិល និងចារឹកថែមទៀត។ ជាងនេះទៅទៀត ការអភិវឌ្ឍគម្រោងទាំងនោះទប់ស្កាត់ ទឹកជំនន់ ដែលជន់លិច ក្រុងពោធិ៍សាត់ និងតំបន់តាមដងស្ទឹងនេះស្ទើរតែរៀងរាល់ឆ្នាំបានទៀតផង។
- ម៉្យាងទៀត បើគេធ្វើការប្រៀបធៀបគម្រោងនេះ ទៅគម្រោងវារីអគ្គិសនីស្ទឹងអាតៃវិញ គឺគម្រោងនេះមានផ្ទៃអាង ៨.៥៩១ ហ.តដែលមានចំណុះទឹកសរុប ប្រមាណ ១.២២៦,៥ លានម$^{៣}$ ធំជាង ផ្ទៃអាងទាំង២ នៃវារីអគ្គិសនីស្ទឹងអាតៃបញ្ចូល គ្នាទៅទៀត (៤.២៣៧ ហ.ត) ហើយការផលិតថាមពលអគ្គិសនីជាមធ្យមបានតែ ៣៦៧,១២GWh ក្នុងមួយឆ្នាំ ប៉ុណ្ណោះ ចំណែកអាតៃ ផលិតបាន ៥០៦,៩៤ GWh ក្នុងមួយឆ្នាំ (អាតៃធំជាង ១,៤ដង)។
- ទោះជាមានផលប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានសង្គមមួយចំនួនយ៉ាងនេះក្តី នៃគម្រោងទាំងនេះក្នុងនោះគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ក៏នឹងផ្តល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងសង្គមជាតិយើង ទាំងមូលផងដែរដូចជាៈ
- ក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិក-កម្មករ ក្នុងពេលសាងសង់របស់គម្រោងទាំងមូល រួមទាំងការសាងសង់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ដែលមានរយៈពេល៤ឆ្នាំនោះ គឺត្រូវការមនុស្សសរុបរហូតទៅដល់ ៤០០នាក់ ក្នុងនោះបុគ្គលិក-កម្មករបរទេស ចំនួន ១០០នាក់ និងពលករខ្មែរជុំវិញតំបន់គម្រោងត្រូវការដល់ចំនួន ៣០០នាក់។
- ចំនួនពលកម្មក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោងៈ ផែនការរបស់ក្រុមហ៊ុននឹងត្រូវការជ្រើសរើសបុគ្គលិក ក្នុងដំណាក់កាលប្រតិបត្តិគម្រោង មានចំនួន ៥០នាក់ ក្នុងនោះបុគ្គលិកខ្មែរចំនួន២៥នាក់ និងបុគ្គលិក-កម្មករបរទេសចំនួន២៥នាក់។ ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង



Draft

សម្រាប់គម្រោងប្រព័ន្ធ ខ្សែអគ្គិសនី និងត្រូវជ្រើសរើសបុគ្គលិក-កម្មករ ចំនួន១៣នាក់ ក្នុងនោះប្រជាពលរដ្ឋមូលដ្ឋានសរុប ០៦នាក់ និង បុគ្គលិក-កម្មករបរទេស ០៧នាក់។

- គម្រោងនេះ នឹងមានការបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជា សម្រាប់ដំណើរការបន្ត ក្រោយពីក្រុមហ៊ុនបញ្ចប់កិច្ចសន្យា ជាមួយរាជរដ្ឋាភិបាលកម្ពុជា។
- ប្រទេសកម្ពុជានឹងមានទំនប់វារីអគ្គិសនីបន្ថែមមួយទៀតដែលមានកម្លាំង៨០MW ហើយវាអាចផលិតថាមពលអគ្គិសនីមធ្យមបាន ៣៦៧,១២ ជីហ្គាវ៉ាត់ម៉ោង (GWh)ក្នុងមួយឆ្នាំ ហើយគម្រោងវារីអគ្គិសនីនេះ នឹងផ្តល់ថាមពល អគ្គិសនីយ៉ាងចំបងអាចឆ្លើយតបដ៏មានប្រសិទ្ធិភាព ចំពោះដំណោះស្រាយប្រភពអគ្គិសនី សម្រាប់ខេត្តពោធិ៍សាត់ ទាំងមូលទៀតផង។ ជាងនេះទៀត គម្រោងវារីអគ្គិសនីនេះនឹងចូលរួមជាមួយគម្រោង វារីអគ្គិសនីផ្សេងៗទៀតក្នុងការផ្តល់ស្ថេរភាព និងឯករាជ្យក្នុងការធានាផ្គត់ផ្គង់អគ្គិសនី ដល់ការប្រើប្រាស់នានាដូចជាតំបន់រោងចក្រឧស្សាហកម្ម តំបន់កសិកម្ម តំបន់ពាណិជ្ជកម្ម តំបន់លំនៅដ្ឋានទីសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិកម្ពុជាដើម្បី រំដោះភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុង និងក្បែរតំបន់គម្រោង និងទូទាំងប្រទេសព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ។
- គម្រោងនេះនឹងកាត់បន្ថយទឹកជំនន់ដែលជន់លិចក្រុងពោធិ៍សាត់ និងតំបន់ទំនាបតាមដងស្ទឹងស្ទើរតែរៀងរាល់ឆ្នាំ។ ជាងនេះទៅទៀត តំបន់អាងនៃវារីអគ្គិសនីនេះ នឹងកកើតកើនឡើងនូវត្រីទឹកសាប ហើយក៏ជាតំបន់ ងាយស្រួលធ្វើការអភិរក្ស នូវត្រីមេពូជ មួយចំនួនទៀតផងព្រោះវាជ្រៅ និងមានទឹកខួបបាំងវស្សា។
- ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន តាមរយៈទេសចរណ៍ជាតិ និងអន្តរជាតិមកតំបន់អាងធំធេង នៃវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ រួចភ្ជាប់ទៅតំបន់អាតៃ និងអូរសោម ដោយធ្វើការទស្សនា និងធ្វើអេកូទេសចរណ៍ទំនប់វារីអគ្គិសនីនេះ រួចវារីអគ្គិសនី ស្ទឹងអាតៃ និងតំបន់អភិរក្សក្រពើអូរសោមផងដែរ ហើយគេក៏អាចទៅមើលវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម បន្ទាប់មក ទៅតំបន់មាត់សមុទ្រនៃខេត្តកោះកុងទៀតផង។
- គម្រោងនេះ នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជាត្រូវកែលំអរផ្លូវចេញចូលពីផ្លូវជាតិលេខ ៥៥ ប្រមាណ៣០គ.ម នៅក្នុងតំបន់ ដែលបង្កឱ្យមានលក្ខណៈល្អប្រសើរ ដល់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់គម្រោង ស្រុកវាលវែង ខេត្តពោធិ៍សាត់។ល។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យសាធារណជនគម្រោងបានសាងសង់ អាគារស្នាក់នៅឱ្យបុគ្គលិកកម្មករ ការិយាល័យ សួនច្បារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត សម្រាប់ការប្រើប្រាស់របស់បុគ្គលិកគម្រោង និងធ្វើឱ្យមានសោភ័ណ្ឌភាព ដល់តំបន់គម្រោងទាំងមូលទៀតផង។
- ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យដីក្នុងតំបន់កើនតម្លៃខ្ពស់ជាងបច្ចុប្បន្ននេះ (២០១៧) ជាពិសេសការប្រើប្រាស់ដីសម្រាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍។ ដោយសារហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងអាចទាក់ទាញអ្នកទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់ គម្រោង និងតំបន់ក្បែរខាងនៅ ថ្ងៃអនាគតយ៉ាងសន្ធឹកសន្ធាប់ទៀតផង ហើយនឹងធ្វើឱ្យខេត្តពោធិ៍សាត់ និងកោះកុង ទាំងមូលក្លាយជាតំបន់ទេសចរណ៍ និងមានធនធានប្រភពថាមពលអគ្គិសនីយ៉ាងសំខាន់មួយសម្រាប់ប្រទេសកម្ពុជា យើងផងដែរ។
- គម្រោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិដោយសារក្រុមហ៊ុន នឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេងឥន្ធនៈ សម្រាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុកពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេល ប្រតិបត្តិគម្រោង ទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

Draft

## ១០.២ អនុសាសន៍ លើគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់

ដើម្បីទទួលបានភាពរលូន ក្នុងការអនុវត្តគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គមនោះ តាមរយៈការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងវារីអគ្គិសនីនេះ SAWAC សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ:

- ក្នុងពេលសាងសង់គម្រោងម្ចាស់គម្រោងត្រូវមានកន្លែងទុកដាក់សំណល់ផ្ទះបាយ (កំប៉ុង ដប ស្បោងប្លាស្ទិក ប្រអប់ស្នោរ សម្រាប់ដាក់បាយ និងសំណល់កម្ទេចអាហារ)ឱ្យបានល្អ ដោយមានរណ្តៅ ត្រឹមត្រូវ ដោយមានការថែទាំជាប្រចាំ។ ជាងនេះទៅទៀតម្ចាស់គម្រោង និងអ្នកម៉ៅការបន្តត្រូវធ្វើបង្គន់អនាម័យឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនកម្មករ បុគ្គលិក គម្រោង។
- ក្រុមហ៊ុនត្រូវធ្វើការសំអាតសំណល់រឹង-រាវ គ្រប់ប្រភេទចេញពីការដ្ឋាន ទីតាំងស្នាក់នៅបណ្តោះអាសន្ន ឃ្លាំង រោងជាង ឱ្យបានស្អាត ហើយយកវាទៅដាក់ក្នុងរណ្តៅសុវត្ថិភាព ឆ្ងាយពីប្រភពទឹក នៅពេលសាងសង់គម្រោងរួច។
- មុនពេលសម្ពោធដាក់ឱ្យផលិតថាមពលអគ្គិសនី អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ពន្ធ័ និងអង្គការ CI គប្បីសហការគ្នា ចុះត្រួតពិនិត្យ ដោយជឿជាក់ថាសំណល់រឹង-រាវទាំងនេះ ត្រូវបានសំអាតដូចបានចែងក្នុងរបាយការណ៍នេះរួចរាល់អស់ហើយ។
- ក្រុមហ៊ុន ត្រូវសហការជាមួយក្រសួង រ៉ែ និងថាមពល ត្រួតពិនិត្យមើលបូឡុង និងខ្សៅនៅតាម បង្គោលអគ្គិសនី ២៣០គ.វ៉ ដោយជឿជាក់ថា ប៊ូឡុង ខ្សៅ ទាំងអស់បានរឹតតឹងត្រឹមត្រូវតាមបច្ចេកទេស និងមិនមាន ការបាត់បង់សូម្បីតែ១គ្រាប់ឡើយ។
- ក្រុមហ៊ុនត្រូវធ្វើសហប្រតិបត្តិការណ៍យ៉ាងពេញទំហឹង (ទាំងថវិកា និងបច្ចេកទេស) ជាមួយរដ្ឋបាលព្រៃឈើ, អង្គការ CI, ក្រសួងបរិស្ថាន , ក្រសួង រ៉ែ និងថាមពល, និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាំដុះព្រៃឈើឡើងវិញ ក្នុងតំបន់ក្បែរខាង និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ ដីព្រៃឈើធ្វើជាកម្មសិទ្ធិខុសច្បាប់ នេះបានន័យថាគម្រោងបានរួមចំណែកស្តារឡើងវិញនូវការបាត់បង់ព្រៃឈើ និងជាជម្រកសត្វព្រៃ ហើយធ្វើឱ្យមាន លំនឹងបរិស្ថាន នៃការអភិរក្សព្រៃការពារ និងតំបន់ការពារទាំងនោះទៀតផង។ ជាពិសេសត្រូវលើស្លាកប៉ាន់ល្មធំៗ នៅក្នុងតំបន់គម្រោងយ៉ាងហោចណាស់ឱ្យបាន៤ ដូចជាសរសេរថា ព្រៃ (តំបន់) ការពារហាមទន្ទ្រានកាន់កាប់ធ្វារ ធ្វើជា កម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ខុសច្បាប់ ជនល្មើសត្រូវដាក់គុករហូតដល់ ១០ ឆ្នាំ ហើយនៅតាម គន្លងខ្សែ២៣០គ.វ៉ ត្រូវដាក់ស្លាកតាមបង្គោលអគ្គិសនីនូវសេចក្តីជូនដំណឹងអំពីចំណីគន្លងខ្សែនៅរៀងរាល់ ២បង្គោលម្តង ឱ្យបានច្បាស់ ងាយមើលឃើញពីចម្ងាយ។
- គម្រោងគួរតែសិក្សាតាមដាន នូវការលិចជ្រាបទឹកចេញពីអាងឱ្យបានហ្មត់ចត់ នៅក្នុងដំណាក់កាលប្រតិបត្តិថែទាំគម្រោង។ ជាងនេះទៅទៀត ត្រូវការសិក្សាតាមដានទឹកក្រោមដី ដោយមានកំណត់ត្រា អំពីនីវ៉ូស្តាទិក និងបរិមាណធារទឹក ទាំងរដូវប្រាំង និងវស្សាច្បាស់សាស់ រួចធ្វើការសន្និដ្ឋានលទ្ធផលប្រចាំឆ្នាំ ដោយដាក់បញ្ចូលក្នុងរបាយការណ៍ការអនុវត្ត វិធានការ ការពារបរិស្ថានប្រចាំឆ្នាំផងដែរ។
- ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យឱ្យបានកម្រិតខ្ពស់ដូចជាការសិក្សាភូគព្ភសាស្រ្ត និងបរិស្ថានក្នុងតំបន់គម្រោងឱ្យបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាបានមិនឱ្យមានការបាក់ទំនប់ បាក់ភ្នំ ឬរញ្ជួយដី។ ត្រៀមគ្រប់គ្រងហេតុការណ៍ដែលអាចកើតឡើងចៃដន្យ ដោយប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់ និងទាន់ពេលវេលា អ្នកជួយសង្គ្រោះ និងសម្ភារសង្គ្រោះ ព្រមទាំងថវិកាសម្រាប់ដោះស្រាយជាបន្ទាន់ទៀតផង។ ជាងនេះទៅទៀត ម្ចាស់គម្រោងត្រូវរកក្រុមហ៊ុនធានារ៉ាប់រងបរទេស ដើម្បីធ្វើការធានាលើជនទី៣ ចំពោះហានិភ័យដែលអាចកើតមានឡើង ដូចជាការបាក់ទំនប់ ការបាក់រអិលភ្នំជាដើម។ល។

- ម្ចាស់គម្រោង គប្បីជ្រើសរើសអ្នកបកប្រែភាសាឱ្យបានគ្រប់គ្រាន់នៅការដ្ឋានសាងសង់គម្រោង ដើម្បីជៀសវាងការយល់ច្រឡំ ធ្វើឱ្យខ្វែងគំនិត ក្នុងការរកដំណោះស្រាយទំនាស់ផ្សេងៗ ដែលអាចកើតមានឡើងរវាងកម្មករបរទេសនិងខ្មែរ។ ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការធ្វើកិច្ចសន្យាការងារជាមួយតំណាងកម្មករខ្មែរឱ្យបានច្បាស់លាស់ត្រឹមត្រូវ ជៀសវាងកើតឡើងនូវទំនាស់ទាំងនោះ។
- ម្ចាស់គម្រោង ត្រូវគ្រោងប្លង់ដំឡើងជាបំពង់បង្ហូរទឹកនៅទីតាំងទំនប់មេ ដោយមានដាក់ប្រដាប់លៃតម្រូវបើកបិតទឹក សម្រាប់បញ្ចេញទឹកមកតំបន់ខាងក្រោមទំនប់ ឱ្យបានយ៉ាងហោចណាស់ ១,៣ ម៣/វិនាទី នៅពេលប្រតិបត្តិថែទាំគម្រោង (ក្នុងគំនូរបច្ចេកទេស សំណង់បង្ហូរទឹកបរិស្ថាននៅឆ្ងាយពីទំនប់មេ៣គ.ម។ ដូចនេះតំបន់កំណាត់ស្ទឹងពោធិ៍សាត់ប្រវែង៣គ.មនេះនឹងខ្វះទឹកសម្រាប់ជីវចម្រុះជាមិនខានជាពិសេសនៅរដូវប្រាំង)។
- ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវចំពោះអ្នកម៉ៅការបន្ត នៅពេលដែលអ្នកម៉ៅការនេះរត់ចោលការងារ ខណៈដែលកម្មករ មិនទាន់បានទទួលប្រាក់ឈ្នួល ឬប្រាក់ខែ ឬមិនបានគោរពតាមកិច្ចសន្យាការងារ និងសៀវភៅបន្ទុក។ ដូចនេះក្រុមហ៊ុន គប្បីបង្អកប្រាក់១៥%ទៅ២០% នៃតម្លៃម៉ៅការសរុប ដែលខ្លួនបានចុះកិច្ចសន្យាជាមួយអ្នកម៉ៅការបន្ត។ នៅពេល ដែលខ្លួនពិនិត្យឃើញថាអ្នកម៉ៅការគ្មាន បញ្ហាអ្វីទាំងអស់នោះ ទើបក្រុមហ៊ុនបើកប្រាក់ទាំងនេះទៅឱ្យអ្នកម៉ៅការទាំងនោះវិញ។
- ម្ចាស់គម្រោងត្រូវមានបុគ្គលិកជំនាញបរិស្ថាន ហើយមានបទពិសោធន៍ខ្ពស់ និងចេះភាសាខ្មែរដើម្បីអនុវត្តផែនការគ្រប់គ្រងបរិស្ថាន តាមរបាយការណ៍នេះ និងធ្វើរបាយការណ៍ទៅក្រសួងបរិស្ថានឱ្យបានទៀងទាត់ទៅតាមផែនការខាងលើនេះ។
- ម្ចាស់គម្រោង ត្រូវរៀបចំធ្វើពង្រាងផែនការដោះស្រាយផលប៉ះពាល់ ដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់អាង (បំលាស់ប្តូរ តាំងលំនៅឋានថ្មីរបស់អ្នករងផលប៉ះពាល់ដោយគម្រោង) និងអនុវត្តន៍ ផែនការនេះ ដោយមានសំណង និងកន្លែងតាំងលំនៅឋានថ្មី ឱ្យបានរួចរាល់មួយឆ្នាំមុនពេលបិទទឹកបំពេញអាង។
- រាល់ដំណាក់កាលនៃគម្រោង ក្រុមហ៊ុនគួរតែអនុវត្តន៍ទៅតាមច្បាប់ ដែលពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យ គម្រោងអភិវឌ្ឍប្រកបទៅដោយជោគជ័យ និងមានចីរភាព។
- ដើម្បីបន្ធូរបន្ថយនូវបណ្តុំផលប៉ះពាល់ខាងលើ សូមឱ្យក្រសួង រ៉ែ និងថាមពល ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំង ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរមូលដ្ឋានពាក់ពន្ធ័ទាំងអស់ គួរធ្វើការពិភាក្សាជាមួយក្រុមហ៊ុនវារីអគ្គិសនីនេះ ដើម្បីរកដំណោះស្រាយនៃការបញ្ចេញទឹកមកតំបន់ខាងក្រោម ឱ្យមានតុល្យភាពគ្នា និងប្រសិទ្ធិភាពខ្ពស់។ លើសពីនេះទៅទៀត សូមក្រសួងបរិស្ថាន ក្រសួងកសិកម្ម ក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ គួរពិចារណា កំណត់ឱ្យម្ចាស់គម្រោង ជាអ្នកប្រមូលយកឈើក្នុងអាង ដោយបង់ថវិកាសម្រាប់ឈើនេះឱ្យរដ្ឋវិញ ព្រោះគោលបំណងសំខាន់ របស់ម្ចាស់គម្រោងគឺធ្វើវារីអគ្គិសនី មិនមែនយកឈើទេ។ ប្រសិនបើឱ្យក្រុមហ៊ុនក្នុងស្រុកជាអ្នកយកឈើទាំងនោះវិញនោះនឹងពិបាកគ្រប់គ្រងការកាប់ឈើក្រៅតំបន់លិចទឹក (តំបន់អាង)។
- ក្នុងករណី ដែលក្រុមហ៊ុនធ្វើការសិក្សាភូគព្ភសាស្ត្រប្រទះឃើញធនធានរ៉ែ ក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រសួងរ៉ែ និងថាមពលជាបន្ទាន់។

Draft

ជាទីបញ្ចប់នេះ ក្រុមហ៊ុនម្ចាស់គម្រោង KTC ដែលតំណាងឱ្យក្រុមហ៊ុនប្រទេសកូរ៉េ និង តំណាង SINOHYDRO ក្រុមហ៊ុនប្រទេសចិន ដែលគម្រោងនេះ មានឱកាសផ្តល់នូវផលប្រយោជន៍ជាច្រើន ដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ដល់ប្រជាពលរដ្ឋក្នុង និងក្បែរ តំបន់គម្រោង ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ ដូចនេះ ក្រុមហ៊ុនយើងខ្ញុំ មានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយបង្កលក្ខណៈងាយស្រួល និងចេញលិខិតអនុញ្ញាត និងទទួលស្គាល់លើរបាយការណ៍វាយតម្លៃហេតុពាល់បរិស្ថាន និងសង្គមពេញលេញនេះជាផ្លូវការដោយអនុគ្រោះ។

ថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៨

Project owner: KTC Cable ( Chairman )

ថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៨

**អ៊ុច សារឿន**

**នាយក** SAWAC Consultants (CAMBODIA)

Draft